**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគដីព្រៃបំរុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងការផ្តល់ សម្បទានដីសម្រាប់អភិវឌ្ឍន៍ ជូនក្រុមហ៊ុន បានយ៉ា គ្រុប សម្រាប់វិនិយោគលើគម្រោងរៀបចំ មជ្ឈមណ្ឌលកំសាន្ត ទេសចរណ៍ ទីក្រុងថ្មី និងសម្រាប់ដាំដុះបន្ថែម ស្តារព្រៃឈើឡើងវិញ និងរក្សាទុកជាព្រៃធម្មជាតិ នៅខេត្តសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៧ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតលេខ ១៦៧៦ សជណ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានចាត់ថ្នាក់ជាផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត នៃដែនដីសម្បទានមានទំហំចំនួន ៧.០០០ ហិកតា (ប្រាំពីរពាន់ហិកតា) ដែលមានទីតាំងស្ថិតនៅក្នុងឃុំល្វាក្រាំង និងឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ។ ទីតាំងប្លង់ដីត្រូវបានកំណត់ក្នុងផែនទីគោលដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យ ហើយមានចំណុចនិយាមកា ដូចខាងក្រោម ÷

| | |
|---|---|
| A : X : 378982 | Y : 1528900 |
| B : X : 387372 | Y : 1528628 |
| C : X : 389646 | Y : 1526060 |
| D : X : 391269 | Y : 1523294 |
| E : X : 395747 | Y : 1521459 |
| F : X : 396995 | Y : 1517222 |
| G : X : 391117 | Y : 1518883 |
| H : X : 389012 | Y : 1520289 |
| I : X : 387583 | Y : 1523824 |
| J : X : 385928 | Y : 1525056 |
| K : X: 384156 | Y : 1526034 |
| L : X : 382465 | Y : 1525478 |
| M: X : 378961 | Y : 1526077 |

ក្នុងនោះមានផ្ទៃដីចំនួន ៣.០០០ ហិកតា សម្រាប់ដាំដុះបន្ថែម ស្តារព្រៃឈើឡើងវិញ និងរក្សាទុកជាព្រៃធម្មជាតិ ដែលមានចំណុចនិយាមកាដូចខាងក្រោម ÷

| | |
|---|---|
| 1 : X : 380734 | Y : 1528843 |
| 2 : X : 379812 | Y : 1525932 |
| 3 : X : 381687 | Y : 1525611 |
| 4 : X : 381880 | Y : 1526167 |
| 5 : X : 381638 | Y : 1526310 |
| 6 : X : 381695 | Y : 1527193 |
| 7 : X : 387670 | Y : 1526325 |
| 8 : X : 386974 | Y : 1524277 |
| 9 : X : 388763 | Y : 1527057 |
| 10: X : 388020 | Y : 1525722 |
| 11: X : 389115 | Y : 1524017 |
| 12: X : 390338 | Y : 1524881 |
| 13: X : 390318 | Y : 1522993 |
| 14: X : 391094 | Y : 1519842 |
| 15: X : 394128 | Y : 1518709 |
| 16: X : 394245 | Y : 1517999 |
| 17: X : 394732 | Y : 1521875 |
| 18: X : 396026 | Y : 1517496 |

ក្នុងនោះមានផ្ទៃដីចំនួន ៤.០០០ ហិកតា សម្រាប់វិនិយោគលើគម្រោងរៀបចំមជ្ឈមណ្ឌលកំសាន្ត ទេសចរណ៍ ទីក្រុងថ្មី ដែលមានចំណុចនិយាមកាដូចខាងក្រោម ÷

| | |
|---|---|
| 1 : X : 380734 | Y : 1528843 |
| 2 : X : 379812 | Y : 1525932 |
| 3 : X : 381687 | Y : 1525611 |
| 4 : X : 381880 | Y : 1526167 |
| 5 : X : 381638 | Y : 1526310 |
| 6 : X : 381695 | Y : 1527193 |
| 7 : X : 387670 | Y : 1526325 |
| 8 : X : 386974 | Y : 1524277 |
| 9 : X : 388763 | Y : 1527057 |

| | |
|---|---|
| 10 : X : 388020 | Y : 1525722 |
| 11 : X : 389115 | Y : 1524017 |
| 12 : X : 390338 | Y : 1524881 |
| 13 : X : 390318 | Y : 1522993 |
| 14 : X : 391094 | Y : 1519842 |
| 15 : X : 394128 | Y : 1518709 |
| 16 : X : 394245 | Y : 1517999 |
| 17 : X : 394732 | Y : 1521875 |
| 18 : X : 396026 | Y : 1517496 |
| B : X : 387372 | Y : 1528628 |
| D : X : 391269 | Y : 1523294 |
| I : X : 387583 | Y : 1523824 |

**មាត្រា ២.-**

ត្រូវបានរំសាយផ្ទៃដីសម្រាប់ផ្ទេរ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀត ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ចេញពីដែនដីព្រៃសម្បទានរបស់ក្រុមហ៊ុន សំរោងវូត ។

**មាត្រា ៣.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ៧.០០០ ហិកតា (ប្រាំពីរពាន់ហិកតា) ដូចមានចែងក្នុងមាត្រាខាងលើ នៃអនុក្រឹត្យនេះ ដែលជាដីព្រៃសម្បទានរបស់ក្រុមហ៊ុន សំរោងវូត ពីដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ ។

**មាត្រា ៤.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ផ្តល់ជូនក្រុមហ៊ុន បានយ៉ា គ្រុប សម្រាប់វិនិយោគលើគម្រោងរៀបចំមជ្ឈមណ្ឌលកំសាន្ត ទេសចរណ៍ ទីក្រុងថ្មី និងសម្រាប់ដាំដុះបន្ថែម ស្តារព្រៃឈើឡើងវិញ និងរក្សាទុកជាព្រៃធម្មជាតិ ស្របតាមគោលការណ៍ និងបទដ្ឋានកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ




| ប្រភេទព្រៃ | ដីសម្រាប់ស្តារព្រៃឈើ ៣០០០ (ហ.ត) | ផ្ទៃដីសម្រាប់វិនិយោគ ៤០០០ (ហ.ត) |
|---|---|---|
| ព្រៃល្បោះ | ១២៦៤ | ២១៧ |
| ព្រៃស្រោង | ៨០៥ | ៨៤២ |
| ដីមិនមានព្រៃ | ៧២ | ៥៤៧ |
| ព្រៃផ្សេងៗ | ៥១២ | ២០០៧ |
| ព្រៃពាក់កណ្តាលស្រោង | ២៧២ | ១៥៥ |
| ព្រៃគុម្ពោតស្ងួត | | ៤០ |
| ព្រៃគុម្ពោតបៃតង | ៦៥ | ១៩១ |

| ID | X | Y |
|---|---|---|
| 1 | 380734 | 1528843 |
| 2 | 379812 | 1525932 |
| 3 | 381687 | 1525611 |
| 4 | 381880 | 1526167 |
| 5 | 381638 | 1526310 |
| 6 | 381895 | 1527193 |
| 7 | 387670 | 1526325 |
| 8 | 386974 | 1524277 |
| 9 | 388763 | 1527057 |
| 10 | 388020 | 1525722 |
| 11 | 389115 | 1524017 |
| 12 | 390338 | 1524881 |
| 13 | 390318 | 1522893 |
| 14 | 391094 | 1519842 |
| 15 | 394128 | 1518709 |
| 16 | 394245 | 1517999 |
| 17 | 394732 | 1521875 |
| 18 | 396026 | 1517496 |